**UNITED NATIONS**
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

*ខាងក្រោមនេះគឺជាសារលិខិតរបស់លោកស្រីល្វីស អាប៊ូរ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ថ្លែងនៅ ក្នុងឱកាសទិវាសិទ្ធិមនុស្ស ១០ ធ្នូ ឆ្នាំ២០០៦ :*

ការយល់ដឹងអំពីអន្លង់នៃភាពក្រីក្រដែលជាប់ផុងដោយមនុស្សរាប់កោដិនាក់ ក្នុងនោះមានបុរស ស្ត្រី និងកុមារ នៅលើពិភពលោក និងការយល់ដឹងពីស្ថានភាពនៃភាពខ្វះខាត និងទុគ៌តភាព ដែលនឹងអាចនាំឱ្យមានគ្រោះមហន្តរាយ ដល់ថ្ងៃអនាគតរបស់យើងទាំងអស់គ្នាដូចម្តេចខ្លះនោះ មានការកើនឡើងយ៉ាងខ្លាំងដែលមិនធ្លាប់មានពីមុនមក ។ ទោះបីជាមានការកើនឡើងនៃការយល់ដឹងប្រកបដោយស្មុគ្រស្មាញ អំពីមូលហេតុដ៏ស៊ាំញ៉ាំដែលបង្កឱ្យមានភាពក្រីក្រ ដោយគិតចាប់ពីការមិនអើពើ និងការរើសអើង រហូតដល់ការផ្លាស់ប្តូរជំហរ ដោយប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ក៏ដោយក៏ទិសដៅដែលនាំទៅដល់ការកាត់បន្ថយភាពក្រីក្រ នៅតែបន្តធ្វើឡើងគ្រាន់តែដើម្បីឆ្លើយតប ទៅនឹងការដង្ហោយសុំរកជំនួយសប្បុរសធម៌ ឬគ្រាន់តែឱ្យមើលឃើញថាមានការគិតឃើញអំពីផលប្រយោជន៍របស់អ្នកដទៃដែរតែប៉ុណ្ណោះ ។

នៅក្នុងឱកាសនៃទិវាសិទ្ធិមនុស្សឆ្នាំនេះ យើងទាំងអស់គ្នាធ្វើការអះអាងជាថ្មីឡើងវិញថា សេរីភាពរួចផុតពីទុគ៌តភាពគឺជាសិទ្ធិ ហើយវាមិនមែនគ្រាន់តែតែជាសេចក្តីមេត្តានោះទេ ។ ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ គឺជាភារកិច្ចដែលអ្នកដឹកនាំទាំងអស់ត្រូវតែបំពេញ ហើយដូចគ្នានេះដែរត្រូវមានកាតព្វកិច្ចដើម្បីធានាថា ជនគ្រប់រូបមានលទ្ធភាពសំដែងមតិដោយសេរី ជ្រើសរើសអ្នកដឹកនាំ និងគោរពសការៈ សាសនា តាមមនសិការរបស់ខ្លួនរៀងៗខ្លួន ។

ប្រទេសទាំងអស់ ទោះបីមាន ឬគ្មានភោគទ្រព្យជាតិរបស់ខ្លួន អាចចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ដោយផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ ឧទាហរណ៍ដូចជា ក្នុងករណីជាច្រើន ការបញ្ចប់ការរើសអើង អាចបំបាត់បាននូវឧបសគ្គនៃការទទួលបាន ការងារសមរម្យ និងអាចផ្តល់លទ្ធភាពឱ្យស្ត្រី និងជនជាតិភាគតិចទទួលបានសេវាចាំបាច់ផ្សេងៗ ។ ការបែងចែកអោយបានប្រសើរឡើងនូវធនធានសម្ភារភាព និងអភិបាលកិច្ចល្អ ដែលមានហើយអាចធ្វើបានដោយរដ្ឋទាំងអស់ ជាឧទាហរណ៍មួយនៃការលុបបំបាត់អំពើពុករលួយ និងការធានាបាននីតិរដ្ឋ ហើយដែលវាគឺជាការទទួលខុសត្រូវរបស់រដ្ឋនីមួយៗ ។

ប៉ុន្តែដោយហេតុថារដ្ឋទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវជាចម្បងចំពោះការអភិវឌ្ឍន៍របស់ខ្លួន ដូច្នេះសហគមន៍អន្តរជាតិ ក៏ត្រូវតែគោរពតាមការប្តេជ្ញាចិត្តរបស់ខ្លួនផងដែរ ចំពោះការដែលខ្លួនគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ អរិយប្រទេសជាច្រើន មិនទាន់ទៅដល់គោលដៅដែលខ្លួនបានព្រមទទួលយកមកអនុវត្តន៍នៅឡើយទេ គឺគោលដៅជំនួយអភិវឌ្ឍន៍ ប៉ុន្តែប្រទេសទាំងនោះបន្តចំណាយថវិកាច្រើនជាងដប់ដងថែមទៀតលើចំណាយយោធា ។ ប្រទេសទាំងនោះក៏បានចំណាយជិតបួនដងនៃថវិកាសំរាប់ជាគោលដៅជំនួយអភិវឌ្ឍន៍របស់ខ្លួន ដើម្បីជួយឧបត្ថម្ភដល់អ្នកបង្កើតផលិតផលកសិកម្មក្នុងស្រុករបស់ខ្លួន ដែលទឹកប្រាក់នេះស្ទើរតែស្មើនឹងផលិតផលសរុបក្នុងស្រុក នៃបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក ។ ការព្រងើយកន្តើយ និងគំនិតចង្អៀតចង្អល់ដោយគិតតែពីផលប្រយោជន៍ជាតិ ដោយអរិយប្រទេសបានធ្វើឱ្យមានឧបសគ្គដល់សិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ ដែលវាដូចគ្នាទៅនឹងស្ថានភាពបណ្តាលមកពីការរើសអើង ដែលកើតមាននៅក្រិតជាតិ ។

នៅក្នុងកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០០៥ អ្នកដឹកនាំនៃប្រទេសនានាលើពិភពលោក បានទទួលស្គាល់ថាការអភិវឌ្ឍន៍ សន្តិភាព សន្តិសុខ និងសិទ្ធិមនុស្ស ត្រូវតែពង្រឹងឱ្យមានទំនាក់ទំនងគ្នាទៅវិញទៅមកកាន់តែខ្លាំងឡើងទៀត ។ នៅក្នុងពិភពលោកមួយ ដែលមនុស្ស ម្នាក់ក្នុងចំណោមមនុស្សប្រាំពីរនាក់ រស់នៅក្នុងសភាពអត់ឃ្លានជាប្រចាំ ហើយដែលភាពមិនស្មើគ្នា និងក្នុងប្រទេសជាច្រើន កំពុងតែរីករាលដាលឡើង លទ្ធភាពរបស់យើងដើម្បីសំរេចគោលដៅ ដែលកិច្ចប្រជុំកំពូលបានគូសបញ្ជាក់ជាថ្មី ថា "ធ្វើឱ្យភាពក្រីក្រទៅជារឿងរ៉ាវ ប្រវត្តិសាស្ត្រ " នោះ នឹងស្ថិតក្នុងភាពមន្ទិលសង្ស័យជាខ្លាំង ប្រសិនបើយើងទាំងអស់គ្នា មិនដោះស្រាយបញ្ហាភាពក្រីក្រ ដោយគិតថាវាជា កត្តាយុត្តិធម៌ និងសិទ្ធិមនុស្សទេនោះ ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org